NSW GOVERNMENT | Education Public Schools

**Walk safely**




# ព័ត៌មានអំពីសុវត្ថិភាពតាមដងផ្លូវ

**លោកអ្នកទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់កូនលោកអ្នក នៅពេលកូនលោកអ្នកធ្វើដំណើរទៅកាន់និងវិលត្រឡប់ពីសាលារៀន។**

## ដើរដោយសុវត្ថិភាព

កាន់ដៃកូនលោកអ្នកជានិច្ច – នៅពេលដើរនៅតាមផ្លូវដើរ ក្នុងចំណតរថយន្ត និងនៅពេលឆ្លងផ្លូវ – រហូតទាល់តែកូនមានអាយុយ៉ាងតិច 8ឆ្នាំ។

នៅពេលកូនលោកអ្នកមានអាយុចាប់ពី 8 ទៅ 10ឆ្នាំ សូមមើលខុសត្រូវកូនឱ្យបានជិតដល់ខ្លាំងនៅពេលកូននៅក្បែរចរាចរណ៍និងនៅពេលឆ្លងផ្លូវ។

**នៅពេលលោកអ្នកសម្រេចអនុញ្ញាតឱ្យកូនលោកអ្នកដែលមានអាយុ 10ឆ្នាំឡើងទៅ ដើរទៅនិងវិលត្រឡប់ពីសាលារៀនដោយខ្លួនឯង សូមពិភាក្សារួមគ្នាអំពីផ្លូវធ្វើដំណើរ។ ហាត់អនុវត្តជាអ្នកថ្មើរជើងមានសុវត្ថិភាពដោយការ៖**

- រក្សាការប្រកាន់ចំហៀងខាងឆ្វេងនៃផ្លូវដើរ
- ដឹងអំពីរថយន្តបើកឆ្លងកាត់ផ្លូវបើកចេញចូលផ្ទះ
- មិនបែកអារម្មណ៍ដោយសារឧបករណ៍ចល័ត ឬដោយអ្នកដទៃ
- ប្រើផ្លូវជម្រើសផ្សេងមួយដែលមានសុវត្ថិភាពដើម្បីទៅផ្ទះ នៅក្នុងអាកាសធាតុមានភ្លៀង
- បង្ហាញការគោរពអ្នកថ្មើរជើងដទៃទៀត។

**ឈប់!** មួយជំហានពីចិញ្ចើមផ្លូវ។
**មើល!** មើលទិសទាំងសងខាងតទៅទៀត។
**ស្តាប់!** សំឡេងនៃចរាចរណ៍ដែលធ្វើដំណើរមក។
**គិត!** តើមានសុវត្ថិភាពក្នុងការឆ្លងផ្លូវឬទេ?

### ដើម្បីទទួលជំនួយបន្ថែម

សូមអានកម្មវិធីអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវរបស់ក្រសួង នៅឯ https://education.nsw.gov.au/road-safety-education ឬបើកមើល https://education.nsw.gov.au ហើយស្វែងរកមើលការអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវ។

**ជំរុញកូនលោកអ្នកឱ្យ៖**

- ប្រើកន្លែងសុវត្ថិភាពជានិច្ចដើម្បីឆ្លងផ្លូវ ដូចជាកន្លែងអ្នកថ្មើរជើងឆ្លងផ្លូវ, ភ្លើងស្តុប ឬកន្លែងឆ្លងផ្លូវសាលារៀនជាដើម បើសិនជាមាន
- ឆែករកមើលរថយន្តបត់ មុនពេលឆ្លងផ្លូវនិងដើរកាត់ផ្លូវបើកចេញចូលផ្ទះ
- កុំសន្មតទាល់តែសោះថា អ្នកបើកបរអាចឃើញពួកគេ ឬឈប់រថយន្តដើម្បីឱ្យពួកគេដើរឆ្លងផ្លូវឡើយ
- សំឡឹងមើលភ្នែកអ្នកបើកបរ ដើម្បីឱ្យពួកគេដឹងថា អ្នកបើកបរបានឃើញពួកគេដែរ
- រង់ចាំទាល់តែអ្នកបើកបរបានបញ្ឈប់រថយន្តទាំងស្រុង មុនពេលពួកគេឆ្លងផ្លូវឬដើរកាត់ផ្លូវបើកចេញចូលផ្ទះ។

